00977222

E138/1/11/2

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 07 / 03 / 2014
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០១៤

**ជូនចំពោះ៖** លោកស្រី អៀង វិជីដា អាណាព្យាបាល
ទូទៅរបស់ជនជាប់ចោទ អៀង ធីរិទ្ធ
ការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ក្រុមមេធាវីការពារក្តី អៀង ធីរិទ្ធ, អង្គភាពគាំពារការការពារក្តី, សហព្រះរាជអាជ្ញា និង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

**កម្មវត្ថុ៖** ចម្លើយតបទៅនឹងសំណើសុំបញ្ជូន អៀង ធីរិទ្ធ ទៅកាន់ប្រទេសថៃដើម្បីព្យាបាលជំងឺ

១. អង្គជំនុំជម្រះបានទទួលសំណើពីលោកស្រី អៀង វិជីដា អាណាព្យាបាលទូទៅរបស់ អៀង ធីរិទ្ធ ដែលបានស្នើសុំបញ្ជូនជនជាប់ចោទ អៀង ធីរិទ្ធ ពីខេត្តប៉ៃលិន ដែលជាលំនៅដ្ឋានបច្ចុប្បន្នរបស់គាត់ទៅកាន់មន្ទីរពេទ្យនៅក្នុងប្រទេសថៃដើម្បីព្យាបាលជំងឺ (ឯកសារ E138/1/11)។

២. អង្គជំនុំជម្រះសាលាដំបូងសូមរំលឹកថា នៅថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) បានបង្គាប់ឲ្យមានរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការលើជនជាប់ចោទ អៀង ធីរិទ្ធ ដោយតម្រូវមិនឲ្យគាត់ចាកចេញពីទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើគ្មានការអនុញ្ញាតជាមុនពីអង្គជំនុំជម្រះសាលាដំបូង (ឯកសារ E138/1/10/1/5/7)។ ដោយ

00977223

គោរពតាមស្មារតីនៃការអនុវត្តរបបនៃការត្រួតពិនិត្យតាមផ្លូវតុលាការនេះ នៅថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឱ្យជនជាប់ចោទ ឬ អាណាព្យាបាលទូទៅរបស់គាត់ត្រូវជូនដំណឹងមកក្រឡាបញ្ជីរបស់អង្គជំនុំជម្រះសាលាដំបូង យ៉ាងហោចណាស់ឱ្យបានរយៈពេលប្រាំពីរ(០៧)ថ្ងៃ មុនពេលស្នើសុំអនុញ្ញាតធ្វើដំណើរទៅបរទេស ហើយនៅក្នុងករណីដែលតម្រូវឱ្យមានការបញ្ជូនទៅទទួលការព្យាបាលជាបន្ទាន់នៅឯបរទេស ជនជាប់ចោទ ឬ អាណាព្យាបាលទូទៅត្រូវជូនដំណឹងមកក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូងឱ្យបានឆាប់តាមការជាក់ស្តែង នៅមុនពេលធ្វើការបញ្ជូនបែបនេះ។ ដីកាបង្គាប់នេះបានបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងនឹងបញ្ជាក់ពីការអនុញ្ញាតឱ្យបញ្ជូនជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីប្រទេសកម្ពុជា តាមការជាក់ស្តែង (ឯកសារ E138/1/10/1/5/8/4)។

៣. អាណាព្យាបាលទូទៅបានជូនដំណឹងមកអង្គជំនុំជម្រះសាលាដំបូងថា កាលពីយប់ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៤ អៀង ធីរិទ្ធ បានដួលពីលើគ្រែគេងរបស់គាត់ "បណ្តាលឱ្យស្ថានភាពសុខភាពមានសភាពដុនដាបយ៉ាប់យ៉ឺន និងឈឺខ្លាំង" គឺរហូតមកដល់ថ្ងៃនេះគាត់នៅតែមិនទាន់អាចក្រោកដើរដោយខ្លួនឯងបាននៅឡើយ (ឯកសារ E138/1/11)។ គ្រូពេទ្យព្យាបាលបានផ្តល់លិខិតបញ្ជាក់ថា ចាប់តាំងពីថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៤ មក សភាពជំងឺរបស់ អៀង ធីរិទ្ធ ពុំបានធូរស្បើយ ហើយបានផ្តល់អនុសាសន៍ឱ្យធ្វើការបញ្ជូនទៅព្យាបាលបន្តនៅប្រទេសថៃ ដែលមានចម្ងាយផ្លូវជិតជាង ដោយមូលហេតុស្ថានភាពអ្នកជំងឺមានការទ្រុឌទ្រោមខ្លាំងជាពិសេស កង់ឆ្អឹងខ្នង និងក្បាលឆ្អឹងភ្លៅ មានបញ្ហា មិនអាចធ្វើដំណើរទៅកាន់ទីក្រុងភ្នំពេញដែលមានចម្ងាយផ្លូវឆ្ងាយបាន (ឯកសារ E138/1/11/1.1)។ អាណាព្យាបាលទូទៅរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បានធានាដល់អង្គជំនុំជម្រះថានឹងនាំគាត់ត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោយពេលព្យាបាលរួច (ឯកសារ E138/1/11)។

៤. ក្រៅពីការជូនដំណឹងពីអាណាព្យាបាលទូទៅ អ្នកជំនាញដែលត្រូវបានតែងតាំងដោយអង្គជំនុំ-ជម្រះបានផ្តល់អនុសាសន៍ថា ជនជាប់ចោទគួរតែបញ្ជូនទៅគ្រូពេទ្យឯកទេសដើម្បីពិនិត្យ។ នៅថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានទទួលលទ្ធផលវាយតម្លៃដោយអ្នកជំនាញលើការថតស្កែនលលាដ៏ក្បាល រួមជាមួយនឹងរបាយការណ៍រៀងរាល់ប្រាំមួយ (០៦) ខែម្តង ដែលបានកត់សម្គាល់ឃើញថា "នៅលើការថតស្កែនលលាដ៏ក្បាលរបស់ អៀង ធីរិទ្ធ ចុះថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១៤ ក្រៅពីមានភស្តុតាងបង្ហាញឱ្យឃើញអំពីភាពរួញខួរក្បាល យើងក៏ឃើញមានភស្តុតាងបង្ហាញឱ្យឃើញអំពីគ្រោះថ្នាក់នៃការស្ទះសរសៃឈាម

ខួរក្បាលចំនួនពីរកន្លែងតូច (គ្រោះថ្នាក់នៃការស្ទះសរសៃឈាមខួរក្បាលតូចៗ (min CVA's) ជំងឺគៀតសរសៃឈាមតូចៗ (mini stroke) ការងាប់ជាលិកាតូចៗ (mini infarcts)) នៅក្នុងថតខួរក្បាលខាងមុខផ្នែកខាងឆ្វេង" (ឯកសារ E138/1/10/1/5/9/6 កថាខណ្ឌ ១១) ហើយក៏បានផ្តល់អនុសាសន៍ថា គប្បីបញ្ជូនជនជាប់ចោទ អៀង ធីរិទ្ធ ឲ្យទៅអ្នកជំនាញផ្នែកប្រព័ន្ធប្រសាទ និងគ្រូពេទ្យព្យាបាលជំងឺទូទៅដើម្បីពិនិត្យមើលក្នុងពេលឆាប់ៗខាងមុខនេះ (កថាខណ្ឌ ១២)។ ភ្លាមៗនោះ អង្គជំនុំជម្រះសាលាដំបូងក៏បានបញ្ជូនរបាយការណ៍នេះទៅកាន់មេធាវីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ និង នៅថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០១៤ ក៏បានបញ្ជូនរបាយការណ៍នេះទៅកាន់អាណាព្យាបាលទូទៅរបស់ អៀង ធីរិទ្ធ តាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ។

៥. ផ្អែកតាមលិខិតបញ្ជាក់ផ្នែកវេជ្ជសាស្ត្រដែលបានផ្ញើជូនអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា ជនជាប់ចោទ អៀង ធីរិទ្ធ តម្រូវឲ្យមានការពិនិត្យ ព្យាបាលបន្ថែមទៀត ហើយដោយសារការធ្វើដំណើរពីខេត្តប៉ៃលិនទៅកាន់ទីក្រុងបាងកក មានភាពងាយស្រួលជាង ព្រមទាំងការសន្យាពីអាណាព្យាបាលទូទៅថានឹងនាំគាត់ត្រឡប់មកប្រទេសកម្ពុជាវិញនោះ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យបញ្ជូនជនជាប់ចោទ អៀង ធីរិទ្ធ ទៅកាន់ទីក្រុងបាងកកប្រទេសថៃ ដើម្បីព្យាបាលជំងឺ។ លោកស្រី អៀង វិជីដា ត្រូវផ្តល់ជូនមកអង្គជំនុំជម្រះនូវលេខទំនាក់ទំនងនៅក្នុងប្រទេសថៃ ហើយលោកស្រី អៀង វិជីដា ត្រូវមានកាតព្វកិច្ចផ្តល់ជូនមកអង្គជំនុំជម្រះនូវការបញ្ជាក់ផ្ទៀងផ្ទាត់អំពីអាស័យដ្ឋានរបស់ជនជាប់ចោទ អៀង ធីរិទ្ធ។ ក្នុងខណៈពេល អៀង ធីរិទ្ធ ស្នាក់នៅក្នុងប្រទេសថៃ អាណាព្យាបាលទូទៅត្រូវធ្វើការបញ្ជាក់ផ្ទៀងផ្ទាត់អំពីអាស័យដ្ឋាននេះឲ្យបានញឹកញាប់ រៀងរាល់ពីរសប្តាហ៍ម្តង។

៦. អង្គជំនុំជម្រះបង្គាប់ឲ្យការិយាល័យរដ្ឋបាលធ្វើការទាក់ទងជាមួយនឹងអាជ្ញាធរពាក់ព័ន្ធនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីអនុញ្ញាតឲ្យជនជាប់ចោទ អៀង ធីរិទ្ធ ធ្វើដំណើរទៅកាន់ប្រទេសថៃ ក្នុងគោលបំណងព្យាបាលជំងឺ និងជួយសម្រួលដល់ការអនុវត្តដីកាបង្គាប់នេះតាមការចាំបាច់។